# គ្រូ

(សម្រង់បរិយាយ តាមធម្មៈព្រះពុទ្ធសាសនា)

**បង្ហាញដោយ ៖ ទឿន សុពូន សីលធម៌ ពលរដ្ឋ ក្រុម ២**

នរណាម្នាក់ក៏មានគ្រូដែរ គ្មានអ្នកណាម្នាក់ដែលចេះដឹង ដោយគ្មានការបង្ហាត់បង្ហាញ ពីលោកគ្រូ អ្នកគ្រូនោះទេ។ ដោយហោចទៅ បើទោះជាមិនបានចូលសាលា ក៏គង់មានឪពុកម្តាយ ជាគ្រូដើមមុនគេបង្អស់ដែរ ហើយពេលខ្លះកូន និងកូនសិស្សមួយចំនួន មិនអាចគិតដល់ផង។ មនុស្សដែលមិនទាន់ចេះដឹងនៅល្ងីតល្ងង់នៅឡើយ តែងចូលទៅសូមការសិក្សា ពីសំណាក់លោកគ្រូ អ្នកគ្រូ តាមសាលារៀងៗខ្លួន ក្នុងតំបន់ផ្សេងៗគ្នា។ បន្ទាប់ពីក្លាយជាសិស្សហើយ គាត់តែងផ្តល់ចំណេះដឹង និងពុទ្ធិជាច្រើន ដោយឥតមានការស្ទាក់ស្ទើរ និងលាក់លាមអ្វីឡើយ។

តើគួរឲ្យឆ្ងល់ដែរឬទេ តើគ្រូមកពីណា ? គ្រូជានរណា? គ្រូត្រូវមានលក្ខណៈសម្បត្តិដូចម្តេច? គ្រូមានតួនាទីដូចម្តេច? គ្រូត្រូវមានវិធីសាស្ត្រដូចម្តេចដើម្បីបង្រៀនសិស្ស? គ្រូត្រូវស្គាល់អ្វី ប្រកាន់យកអ្វី និងលះបង់អ្វី?

លំយល់ដឹងដែលនឹងទទួលបានយ៉ាងច្បាស់លាស់ ស្តីអំពីគ្រូនោះ ដំបូងត្រូវដឹងថាគ្រូមកពីណា ? «**គ្រូ**» មកពីបាលី និងសំស្ក្រឹតថា **គរុ** [ អានថា ៖ គៈរុ ] (គរុ = គរ > គ្រ +ុ >ូ = គ្រូ ) ជា (គុ.) ប្រែថា ធ្ងន់ ចម្បង ធំ ដូចពាក្យថា គរុទោស (ទោសធ្ងន់) គរុកម្ម (កិច្ចការចម្បង) គរុធម៌ (ធម៌ដ៏ចម្បង)។ **គ្រូ** (ន) មានន័យថា អ្នកដែលមានចិត្តធ្ងន់ អ្នកដែលគេគួរគោរព ពោលគឺ អ្នកបង្ហាត់បង្រៀនផ្តល់ចំណេះដឹង ចំណេះធ្វើ និងបុគ្គលិកលក្ខណៈល្អ ដល់សិស្សានុសិស្ស។

ក្នុងព្រះពុទ្ធសាសនា ខាងសង្គមសង្ឃច្រើនប្រើពាក្យ អាចារ្យ និងឧបជ្ឈាយ៍ ដែលមានន័យដូចនឹងគ្រូដែរ។ **អាចារ្យ** មានន័យថា អ្នកប្រៀនប្រដៅ អ្នកបង្ហាត់មារយាទ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ អ្នកប្រព្រឹត្តអំពើជាប្រយោជន៍ដល់សិស្ស ឬជាមនុស្សដែលសិស្សគប្បីចូលទៅអាស្រ័យ ដើម្បីការសិក្សារៀនសូត្រ ឬឲ្យន័យថា ជាអ្នករិះរក ប្រតិបត្តិ អនុវត្ត គ្រប់មធ្យោបាយដើម្បីឲ្យសិស្សបានចេះដឹង។ **ឧបជ្ឈាយ៍** ឬគ្រូបាធ្យាយ មានន័យថា អ្នកសម្លឹងរំពៃមើលនូវទោសតូច និងទោសធំរបស់សិស្ស ហើយដាស់តឿនក្រើនរំឭក។

ព្រះមង្គលាចារ្យ (អ្នកប្រាជ្ញព្រះពុទ្ធសាសនា) បានប្រតិស្ឋចំណារស្តីអំពីគ្រូ ក្នុងគម្ពីរមង្គលត្ថទីបនី ភាគ៣ ត្រង់ កថាខណ្ឌទី២៦១ ថា៖ **គរុ នាម គរុភាតព្វា បុគ្គលា** ប្រែថា ៖ បុគ្គលទាំងឡាយដែលគួរធ្វើឲ្យធ្ងន់ ឈ្មោះថាគ្រូ ។ **គរូតិ គារវយុត្តបុគ្គលា** ប្រែថា ៖ បុគ្គលដែលគេគួរគោរព ឈ្មោះថាគ្រូ។

ពិតណាស់ បុគ្គលដែលគេគួរគោរពទាំងនោះ អ្នកប្រាជ្ញទាំងឡាយ ហៅថាគ្រូ ព្រោះគាត់ធ្វើឲ្យអណ្តែតឡើង ពោលគឺធ្វើឲ្យសិស្សទាំងអស់ និងសង្គមទាំងមូល លេចធ្លោមានមុខមានមាត់ខ្ពង់ខ្ពស់។

គ្រូ គឺជាអ្នកបង្ហាញ ទ្រោលបំភ្លឺ ផ្លូវជីវិតប្រកបដោយសុភមង្គលដល់សិស្ស ជាអ្នកខ្ពង់ខ្ពស់ និង

ជាអ្នកប្រាជ្ញប្រាកដប្រជា។

គ្រូ គឺជាអ្នកធ្ងន់ គឺធ្ងន់ទាំងកាយ ធ្ងន់ទាំងចិត្ត ។ លោកប្រៀបដូចទៅនឹង ឆត្រថ្ម ដែលភាសាអ្នកស្រុកហៅថា ពើងឆត្រ ពោល គឺគ្រូ ត្រូវរងសម្ពាធដ៏ធ្ងន់ធ្ងរ ពីសិស្ស មាតាបិតាសិស្ស អ្នកស្រុក និងសង្គម ដែលផ្ដើនព្រហើន ចំអកឡកលើយ រិះគន់តិះដៀលសព្វសារពើ។ ជាងនេះទៅទៀតគ្រូ ត្រូវអត់ធ្មត់ រាល់ការលំបាកជាច្រើន ដូចជា ការរស់នៅឆ្ងាយផ្ទះ ការហូបចុក ការស្នាក់នៅ និងការប្រឹងប្រែងប្រៀនប្រដៅកូនគេ។ មនុស្សភាគច្រើន ពេលគ្រូប្រដៅកូនឥតកំណើត របស់គាត់មិនបាន ដោយហេតុថាកូននោះវាខិលខូច ពាលាអាវ៉ាសែ មិនយកចិត្តទុកដាក់ស្ដាប់បង្គាប់គ្រូ បែរជាបន្ទោសថាគ្រូ ឥតកំណើត គ្រូមិនផេះ។ វាគួរឲ្យឈឺចាប់ខ្លាំងណាស់ តែគ្រូត្រូវតែទ្រាំ។ ប៉ុន្តែបើគ្រូអប់រំកូនគេបានល្អ បានខ្ពង់ខ្ពស់វិញនោះ គេថាមកពីពូជគេល្អ ពូជគេមានកំណើត ឈាមអណ្ដែត កាត់បានទៅ តា យាយ អ៊ំ ពូ មីង...ដោយហោចទៅសូម្បីតែពាក្យសរសើរគ្រូបន្តិចក៏គ្មានទាល់តែសោះ។ ទាំងនេះ គិតទៅគួរឲ្យស្រណោះលោកគ្រូអ្នកគ្រូខ្លាំងណាស់ ដោយហេតុថា ធ្វើគុណដល់គេ គេដាក់ពិន្ទុឲ្យក្រោមសូន្យដូចគ្នា។ ទាំងនេះ បញ្ជាក់យ៉ាងច្បាស់ថា គ្រូជាអ្នកធ្ងន់ ជាអ្នករងនូវមហាទម្ងន់ ដូចជាឆត្រថ្មដែលរងនូវទម្ងន់រាប់ពាន់ម៉ឺនតោន។

គ្រូ ជាវេជ្ជបណ្ឌិតដ៏ចំណាន លើសពីពេទ្យទូទៅ ដែលអាចព្យាបាលបានតែ រោគខាងក្នុង និងខាងក្រៅសារពាង្គកាយមនុស្សតែប៉ុណ្ណោះ។ ចំណែកគ្រូជា វេជ្ជបណ្ឌិត ព្យាបាល រោគល្ងង់ រោគអវិជ្ជា រោគអប្បប្រាជ្ញារបស់សិស្ស ហើយអភិវឌ្ឍឲ្យក្លាយជាកវីបណ្ឌិត អ្នកចេះដឹងមានឈ្មោះបោះសំឡេងល្បីល្បាញកក្រើកប្រទេស តំបន់ និងពិភពលោក។

គ្រូ ជាវិស្វករដ៏ប៉ិនប្រសប់ច្នៃព្រលឹងកូនខ្មែរ អប់រំកូនខ្មែរ ឲ្យយល់ដឹងពី អរិយធម៌ វប្បធម៌ សីលធម៌ ភាសា សាសនា... និងមានចំណេះដឹង ជំនាញ និងអភិវឌ្ឍបុគ្គលិកលក្ខណៈសិស្សថែមទៀត។

រួមសេចក្ដីមក គ្រូ ជាអ្នកអប់រំប្រៀនប្រដៅសិស្ស អ្នកទ្រោលបំភ្លឺបង្ហាញផ្លូវសិស្ស ជាមនុស្សដែលគេគួរគោរព ជាវេជ្ជបណ្ឌិតដ៏ចំណាន និងជាវិស្វករច្នៃព្រលឹង ។

## លក្ខណៈសម្បត្តិគ្រូបង្រៀន

**១.សុខភាព** ៖ គ្រូត្រូវមានសុខភាពល្អទាំងកាយ និងផ្លូវចិត្ត គឺ ៖

**-សុខភាពផ្លូវកាយ** ៖ រូបរាងកាយរឹងមាំ ជាអ្នកមិនមានរោគរ៉ាំរ៉ៃ ឈឺជាៗមួយថ្ងៃកាត់មួយថ្ងៃកោរនោះទេ ។ ចំណុចនេះ តម្រូវឲ្យគ្រូចេះថែទាំសុខភាពតាមគ្រប់មធ្យោបាយដើម្បីឲ្យកាយសម្បទាមាំមួន មានកម្លាំង ពលំ ដែលជាកត្តាមួយធ្វើឲ្យមាននិយតភាពក្នុងការបង្រៀន និងរៀន។

**-សុខភាពផ្លូវចិត្ត** ៖ គ្រូត្រូវមានចិត្តត្រជាក់ មិនឆេវឆាវ ឬឆាប់ខឹងទេ។ ជាអ្នកពូកែគិតមានគំនិតឆ្លាតវៃ មិនធុញថប់ក្នុងការអប់រំ រីករាយជានិច្ចចំពោះការបង្ហាត់បង្រៀន...។

**២.សមត្ថភាព** ៖ គ្រូត្រូវមានសមត្ថភាព ផ្នែកចំណេះដឹង ជំនាញគ្រប់គ្រាន់ទាំងជំនាញ ឯកទេសនឹងចំណេះដឹងទូទៅ ក្នុងការបង្ហាត់បង្រៀន និងមានគរុកោសល្យច្បាស់លាស់។ ស្របគ្នានេះ គ្រូត្រូវចេះអភិវឌ្ឍសមត្ថភាពរបស់ខ្លួនតាមសម័យកាល និងស្វ័យសិក្សា ស្វ័យស្រាវជ្រាវជានិច្ច។

**៣.គុណធម៌** ៖ គ្រូត្រូវប្រកាន់យកអាកប្បកិរិយាទន់ភ្លន់ តែមិនមែនទន់ជ្រាយទេ មានចរិតសុភាពរាបសា ស្រគត់ស្រគំ រស់រាយរាក់ទាក់ មិនឆ្មើងឆ្មៃ មានចរិយាល្អ ប្រកាន់ខ្ជាប់នូវសីលធម៌ សុជីវធម៌ មិនឡិឡក់ លេងសើចឥតប្រយោជន៍ច្រើន ឬស្និទ្ធស្នាលជ្រុលហួសហេតុពេកជាមួយសិស្ស និង ត្រូវជាមនុស្សរឹងប៉ឹង ម៉ឺងម៉ាត់ ហ្មត់ចត់ ប្រាកដប្រជា។ មិនតែប៉ុណ្ណោះគ្រូគួរ ចេះធ្វើទាន រក្សាសីល និងចម្រើនភាវនា និងកាន់ខន្តីធម៌ជានិច្ច។

## តួនាទីគ្រូបង្រៀន

**១.សុវិនីតំ វិនេន្តិ** គ្រូត្រូវអប់រំដឹកនាំសិស្សឲ្យបានល្អ ៖ ទោះជាសិស្សប្រភេទណាក៏ដោយ ក៏មិនត្រូវបណ្តែតបណ្តោយឡើយ ត្រូវធ្វើឲ្យសិស្សមានចរិយាមារយាទល្អ សណ្តាប់ធ្នាប់ល្អ ឥរិយាបថ និងអាកប្បកិរិយាល្អ មានអធ្យាស្រ័យល្អ ចេះសន្តោស យោគយល់គ្នា និងខំប្រឹងប្រែងកែលម្អសិស្សឲ្យបានរឿយៗ ដើម្បីក្លាយខ្លួនពួកគេជាសិស្សល្អ មនុស្សល្អ ក្នុងសង្គម។

**២.សុគ្គហិតំ គាហាបេន្តិ** គ្រូត្រូវបង្រៀនសិស្សដោយល្អ ៖ គឺបង្ហាត់ដោយយកចិត្តទុកដាក់ មានមេរៀន វិធីសាស្ត្របង្រៀន កិច្ចតែងការច្បាស់លាស់ និងសម្ភារឧបទេសគ្រប់គ្រាន់ មិនមែនបង្រៀនឲ្យតែរួចខ្លួននោះទេ មិនបង្រៀនគំរោះគំរើយ មិនម្និកម្ន៉ក់ មិនគំហកកំហែង គឺបង្រៀនដោយមេត្តាចិត្ត និងករុណាចិត្ត ស្រឡាញ់រាប់អាន អាណិតអាសូរ ក្នុងបំណងប្រាថ្នាឲ្យសិស្សយល់ និងចេះដឹង។

**៣.សព្វសិប្បេសុ តំ សមត្ថាយិនោ ភវន្តិ** គ្រូត្រូវបង្ហាត់សិស្សឲ្យចេះគ្រប់មុខវិជ្ជា ឬឲ្យអស់ពីសមត្ថភាពតាមជំនាញ ៖ គ្រូត្រូវពន្យល់ណែនាំសិស្សដោយល្អ ឲ្យសិស្សបានដឹង បានចេះ គ្រប់មុខវិជ្ជា ឬបង្រៀនឲ្យអស់សមត្ថភាពទៅតាមជំនាញ ដែលធ្វើឲ្យសិស្សអាចអនុវត្តបានដោយខ្លួនឯង ឬអាចទីពឹងខ្លួនឯងបានដោយចំណេះដឹងដែលគ្រូផ្តល់ឲ្យច្បាស់លាស់ ។ ចំណុចនេះ គ្រូត្រូវបង្ហាត់សិស្សដោយឥតលាក់លាមចំណេះ ដូចជាម៉ោងរដ្ឋមិនបង្ហាត់បែរជាទុកទៅបង្ហាត់ក្រៅម៉ោងនោះទេ ព្រោះថា ចំណេះដឹងទាំងនេះ មិនមែនស្លាប់ទៅយកទៅជាមួយខ្លួនបាននោះទេ។

**៤. មិត្តមច្ចេសុ បដិវេទេន្តិ** គ្រូត្រូវលើកតម្កើងសិស្សក្នុងទីប្រជុំ ចំពោះមុខមិត្រ មន្ត្រីរាជការ ៖ ការសរសើរលើកតម្កើងដោយស្មោះ សរសើរតាមការពិតត្រង់ចំណុចដែលគួរសរសើរ ហើយពេលស្ងាត់កំបាំងជួយប្រាប់ និងជួយកែកំហុសជ្រុលជ្រួស ។ ប្រសិនបើស្តីបន្ទោសក្នុងទីប្រជុំ ក៏គួរនិយាយជាទូទៅកុំពោលចុចសំដៅចំឈ្មោះ ធ្វើឲ្យសិស្សបាក់ទឹកចិត្ត។ ធ្វើដូច្នេះ សិស្សអាចដឹងកំហុសហើយរីករាយក្នុងការកែលម្អ រមែងដល់នូវភាពរុងរឿងដូចព្រះចន្ទផុតចាកពពក។

**៥. ទិសាសុ បរិត្តាណំ ករោន្តិ** គ្រូត្រូវការពារសិស្សគ្រប់ទិស ក្នុងទីទាំងពួង ៖ អន្តរាយកើតតាមផ្លូវណាត្រូវការពារត្រង់ផ្លូវនោះ ដោយការប្រុងប្រយ័ត្នបំផុត ពោលគឺការពារសិស្សដែលកំពុង វង្វេងស្រវឹងនឹងចំណេះដឹង ហើយយកចំណេះដឹងនោះទៅប្រើប្រាស់ក្នុងផ្លូវខុស ប្រព្រឹត្តិផ្តេសផ្តាស់ បៀតបៀនអ្នកដទៃដោយប្រការណាមួយនោះ គ្រូត្រូវជួយកែលម្អ និងការពារ ហាមប្រាម មិនឲ្យប្រព្រឹត្តតទៅទៀត។

# វិធីសាស្ត្របង្រៀន

**១.មិយោ** ៖ គ្រូត្រូវធ្វើខ្លួនឲ្យសិស្សស្រឡាញ់រាប់អាន មានភាពស្និទ្ធស្នាល ធ្វើឲ្យសិស្សចង់និយាយលេង ចង់ប្រឹក្សា ហ៊ានសាកសួរ ហ៊ានឆ្លើយឆ្លង។ គ្រូត្រូវប្រើពាក្យពេចន៍ផ្អែមល្ហែម មិនគំហកកំហែង គំរាមសម្លុត ដែលធ្វើឲ្យសិស្សខ្លាចរហូត មិនហ៊ាននិយាយស្តីជាមួយ ដល់ថ្នាក់និយាយពីក្រោយ រហូតហ៊ានកុហកគ្រូ ព្រោះខ្លាចក៏មាន។ ការដែលធ្វើឲ្យក្មេងខ្លាចខ្លាំងពេកនេះ មិនត្រឹមត្រូវទេ គប្បីប្រើពាក្យពីរោះពិសា កាយវិការទន់ភ្លន់ មិនត្រូវពាក់មុខយក្សដាក់សិស្សព្រឹកល្ងាច ឬប៉ះដៃយកដៃប៉ះជើងយកជើងទេ។

**២.គរុ** ៖ គប្បីធ្វើខ្លួនឲ្យជាទីគោរពរបស់សិស្ស ឲ្យជាគម្រូដ៏ល្អរបស់ក្មេង។ ធម្មតាបើគ្រូប្រព្រឹត្តយ៉ាងណា សិស្សក៏នឹងចម្លងគម្រូយ៉ាងនោះមិនខាន។ ពាក្យថា «ពុតគ្រូកុំគ្រាប់ ច្បាប់គ្រូត្រូវយក» មិនគួរយកមកប្រើទេ បើគ្រូខ្លះប្រព្រឹត្តល្បែងស្រី ល្បែងស្រា ល្បែងស៊ីសង និងអបាយមុខផ្សេងៗ ប្រព្រឹត្តខ្លួនថោកទាបរហូតសិស្សមើលងាយមើលថោក ឬអស់សង្ឃឹមពឹងគ្រូលែងបាន។

**៣.ភាវនានីយោ** ៖ ជាអ្នកលើកតម្កើងតម្កល់ខ្លួន ឲ្យសមទៅនឹងបញ្ញា ចំណេះដឹង ថែមទាំងចេះអប់រំខ្លួន អភិវឌ្ឍខ្លួនឲ្យកាន់តែប្រសើរជានិច្ច ដែលជាហេតុធ្វើឲ្យសិស្សរីករាយ ព្រោះគ្រូជាមនុស្សល្អមានគេកោត គេសរសើរ ។ ចំណុចនេះជារឿងដែលគ្រូគ្រប់រូបត្រូវសិក្សាបន្ថែម ឲ្យទាន់ហេតុការណ៍ បច្ចុប្បន្នភាពសង្គម មិនមែនជាគ្រូហួសសម័យដែលសិស្សមើលងាយថាបុរាណពេក ហើយក៏មិនទំនើបហួសហេតុពេកដែរ «បុរាណមិនយឺត សម័យមិនបរទេស»។

**៤.វត្តា ច** ៖ ចេះនិយាយបានជាផលប្រយោជន៍ ចេះឧទ្ទេស ចេះសន្ទនា ចេះបកស្រាយ ចេះពន្យល់ចេះពណ៌នា និងដឹងថាពេលណាត្រូវប្រើវិធីសាស្ត្រណា ពេលណាគួរនៅស្ងៀម ពេលណាត្រូវសម្របសម្រួលជាដើម។ ពេលសិស្សធ្វើខុសគ្រូត្រូវណែនាំដោយល្អ មានតិចនិក ក្នុងការប្រៀនប្រដៅ មិនទៅទាំងទទឹងទិស ឬក៏បណ្តោយសិស្សរហូតដល់និយាយលែងស្តាប់គ្នាបាននោះទេ។

ព្រះបាទជ័យចេស្តា ព្រះមហាក្សត្រខ្មែរ នាស.វ ទី១៧ បានរៀបចំវិធីសាស្ត្រសួរចម្លើយ អ្នកជាប់ក្តី៤យ៉ាង ហៅថាល្បិចចៅក្រម ដែលយើងអាចយកមកច្នៃ រៀបចំទៅជាការអប់រំសិស្សបាន។ ល្បិចនោះ គឺមន្ទលេន សេនបទ មណ្ឌុកជ សីហលោ។

**ក.មន្ទលេន** ៖ ប្រែថា ទន់ ទន់ភ្លន់ ស្រទន់ សន្សឹមៗ តិចៗ ជាការអប់រំណែនាំ សាកសួរដោយកាយវិការទន់ភ្លន់សុភាព មិនកញ្ជក់កញ្ឆែង ឧបមាដូចជាទឹក ដែលហូរចូលត្រពាំងរិញៗ លុះត្រាតែពេញមិនហូរគំហុកខ្លាំងទាល់តែបាក់ច្រាំងនោះទេ ដូចពាក្យស្លោកថា «សឹមកុំបំបោល ក្រែងមិនដល់ដូចប្រាថ្នា» ឬ «ត្រឹកៗដេកផ្ទះ រូតរះដេកផ្លូវ»។

**ខ.សេនបទ** ៖ ប្រែថា ដំណើរសត្វក្លែងឆាបកូនមាន់។ លោកឲ្យឧទាហរណ៍ថា សត្វក្លែងមុននឹងឆាបកូនមាន់វាត្រូវហើររេរា ស្ទង់មើលសិន លុះតែមានឱកាសល្មមឆាបឆក់បាន វាក៏សម្លបស្លាបឆាបចុះហើយហើររេឡើងទៅវិញ។ ដូចគ្នាដែរ សិស្សខ្លះត្រូវប្រើល្បិចកិច្ចកល ឬចាំឱកាសហុចឲ្យបន្តិច ទើបគួរនឹងប្រដៅ បើទៅទាំងពីសពាសមិនបានផលឡើយ។

**គ.មណ្ឌុកជ** ៖ ប្រែថា ដំណើរកង្កែប ។ ធម្មតាកង្កែប វាជាសត្វដែលលោត បង្អង់ហើយទើបទៅមុខទៀត។ ត្រង់នេះអាចយកជាគតិថា ធម្មតាការអប់រំ ការបង្រៀន ប្រៀនប្រដៅ តាំងពីព្រលឹមទល់ព្រលប់ ១ខែ ៣០ ថ្ងៃគ្មានលស់ថ្ងៃណានោះ ប្រាកដជាគ្មានសិស្សណាទ្រាំបានទេ ត្រូវទុកឱកាសឲ្យគ្នាយកទៅកែខ្លួនផង ឬបើមានការស្តីប្រដៅ ក៏ត្រូវមានរង្វាន់ជាគូដែរ (ពេលកង្កែបសម្រាកស៊ី)។

**ឃ.សីហលោ** ៖ ប្រែថា កាន់យក កាន់តាម សីហៈ គឺសត្វតោ។ ធម្មតាសត្វតោ ជាសត្វមានអំណាចលើសសត្វនានា ព្រោះវាមានកម្លាំងខ្លាំង អាចសន្ធប់សត្វដទៃឲ្យស្លុតបាន ។ សិស្សខ្លះ និយាយពាក្យទន់មិនស្តាប់ ធ្វើល្បិចមិនបាន ស្តីប្រដៅមិនបាន គ្រូត្រូវប្រើរបៀបសីហៈ គឺត្រូវប្រើទណ្ឌកម្ម និងពិន័យឲ្យរាងចាល។ ទណ្ឌកម្មបានដល់ ការឲ្យចម្លង អាន ឬសរសេរច្រើនចប់ច្រើនសា ឬគម្រាមដោយសម្តីបន្តិចបន្តួច។ សូមប្រយ័ត្នការប្រើប្រាស់រំពាត់ ក្នុងការធ្វើទណ្ឌកម្មមិនត្រឹមត្រូវឡើយ គ្រូត្រូវរកវិធីដាក់ទណ្ឌកម្ម និងពិន័យបែបណាឲ្យស្របទៅនឹងច្បាប់គរុកោសល្យ។

**៥.ខមនត្ថមោ** ៖ អត់ធន់ចំពោះពាក្យសម្តី គឺពេញចិត្ត មិនធុញទ្រាន់ នឹងការស្តាប់សំណួរ ការពិភាក្សា ការរិះគន់ ការបញ្ចេញមតិ យោបល់ ពីសិស្សជានិច្ច។ លោកគ្រូអ្នកគ្រូត្រូវគិតថា សិស្សមានចរិតមួយ គឺឆ្ងល់ហើយចង់ចេះ ដូច្នេះ ត្រូវអត់ធន់ចំពោះសំណួរសិស្ស កុំគប្បីខឹង ឬក្រេវក្រោធ ឬធ្វើមុខមិនសប្បាយចិត្តពេលសិស្សសួរ ឬសុំយោបល់ពីខ្លួននោះ។ ការអត់ធន់នេះ នឹងអាចធ្វើឲ្យសិស្សរឹតតែគោរព និងលើកតម្កើង យើងថាជាបុគ្គលដែលមានប្រយោជន៍ចំពោះជីវិតគេ។

**៦.គម្ភីរញ្ច កថំ កត្តា** ៖ អាចពន្យល់រឿងរ៉ាវដែលជ្រៅៗ រឿងរ៉ាវដែលពិបាកៗ ឲ្យសិស្សយល់និងកាន់តែបែកប្រាជ្ញាឡើង។ ចំពោះគ្រូពុំសូវមានចំណេះដឹងខ្ពស់ មិនអាចពន្យល់សិស្សបាន ក៏គួរប្រាប់សិស្សតាមត្រង់ ហើយប្រាប់ថាចាំទៅរក ចាំទៅសួរលោកនេះ លោកនោះ ឬរកសៀវភៅមកអានខ្លួនឯង ឬក៏នាំទៅជួបលោកអ្នកប្រាជ្ញដែលអាចឆ្លើយបាន។ ធ្វើយ៉ាងនេះ ឈ្មោះថាយើងអាចស្រាយកង្វល់របស់សិស្សបាន។ ម្យ៉ាងទៀត បើខ្លួនឆ្លើយមិនកើត សូមកុំឆ្លើយនាំឲ្យខុស បើខ្លួនអស់ចំណេះហើយ ទាល់គំនិតហើយ គប្បីរកគ្រូផ្សេងទៀតដែលល្អជាងខ្លួន ឲ្យមកបង្រៀនជំនួស ឲ្យកាន់តែច្បាស់លាស់ មិនគប្បីខ្លាចសិស្សចេះជាងខ្លួននោះទេ។

**៧.នោ ចដ្ឋានេ និយោជយេ** ៖ មិនឲ្យសិស្សប្រព្រឹត្តធ្វើក្នុងរឿងខុសឆ្គង រឿងវិនាស ឬរឿងដែលមិនមានប្រយោជន៍ ។ ត្រូវដាស់តឿក្រើនរំឭកសិស្ស ពេលជជែកឡូឡា រំខានសិស្សដទៃ និយាយពាក្យអសុរោះ ប្រឡែងគ្នា ក្នុងថ្នាក់ ពេលកំពុងរៀន ឲ្យមានឥរិយាបថល្អឡើង។ ម្យ៉ាងទៀត បើសិស្ស រៀនជក់បារី រៀនផឹកស្រា រៀនលេងល្បែង រៀនដេរបញ្ចោរ ជាដើមគ្រូត្រូវប្រដៅអប់រំសិស្សឲ្យបានល្អឡើង កុំអប់រំតែចំណេះដឹងតែម្យ៉ាង ឯបុគ្គលិកលក្ខណៈសិស្សមិនខ្វល់នោះមិនកើតទេ។

គោលការណ៍អប់រំទាំង ៧យ៉ាងនេះ លោកគ្រូ អ្នកគ្រូ គប្បីយកចិត្តទុកដាក់ ឲ្យបានជិតដល់ ព្រោះអ្នកមានតួនាទីជាគ្រូ បើអ្នកបង្ហាត់បង្រៀនសិស្សមិនបានល្អសិស្សអ្នកប្រាកដជាប្រឡងធ្លាក់មិនខាន។

បន្ទាប់ពីវិធីសាស្រ្តខាងលើ យើងមានវិធីសាស្រ្ត ៨យ៉ាងផ្សេងទៀត ជាគន្លឹះសម្រាប់បង្ហាត់បង្រៀន ក៏ដូចជាបណ្តុះប្រាជ្ញាសិស្សផងដែរ៖

១.ឲ្យសិស្សរៀនសូត្រសព្វវិជ្ជាសិល្បសាស្ត្រ គ្រប់យ៉ាងទៅតាមសម័យនិយម ទៅតាមលទ្ធភាពគ្រូ និងដែលសិស្សអាចទៅបាន។

២.ណែនាំឲ្យសិស្សចូលចិត្តការអាន និងអានតែសៀវភៅណាដែលមានប្រយោជន៍ ។

៣.បើកឱកាសឲ្យសិស្សបានសាកសួរ និងជំរុញឲ្យសិស្សចេះឆ្ងល់ ចេះសួរ មិនគប្បីធុញទ្រាន់ចំពោះសំណួរសិស្សឡើយ «ចម្ងល់ ជាប្រភពនៃបញ្ញា»។

៤.លើទឹកចិត្ត និងផ្តល់ឱកាសឲ្យសិស្សបញ្ចេញមតិយោបល់ ពិភាក្សាជាមួយខ្លួន ឬបណ្ឌិតអ្នកប្រាជ្ញ មិនគប្បីបង្ក្រាបគំនិតសិស្សឡើយ ដូចពុទ្ធភាសិតថា «**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ** ការជជែកពិភាក្សាគ្នា ជាមង្គលដ៏ឧត្តម»។

៥.ផ្តល់ឱកាសឲ្យសិស្សចេះគិត វិភាគ រកហេតុផល ដោយខ្លួនឯង យើងគ្រាន់តែជាអ្នកណែនាំ និងសម្របសម្រួល។

៦.រៀបចំ និងជួយឲ្យសិស្សមានឱកាស បានអនុវត្តនូវអ្វីដែលគេចេះ ហើយជាការមានប្រយោជន៍ គ្រូគួរដាក់កិច្ចការ លំហាត់ ឬសកម្មភាពអ្វីមួយឲ្យសិស្សបានធ្វើ បានអនុវត្ត។

៧.លើទឹកចិត្តសិស្ស ឲ្យចេះស្រាវជ្រាវ សរសេរអត្ថបទ កំណាព្យ រឿងខ្លី ឬទស្សនៈអ្វីមួយដែលសិស្សបានឃើញ បានឮ បានដឹង ដើម្បីជាការហ្វឹកហាត់ឲ្យសិស្សកាន់តែពូកែឡើង។

៨.ការធ្វើសមាធិ គឺតម្កល់ចិត្តឲ្យស្ងប់ និងអាចជាការជួយយ៉ាងខ្លាំង ក្នុងការឲ្យសិស្សរៀនសូត្រឆាប់ចេះ ឆាប់ចាំ និងចាំមិនងាយភ្លេច។ ដូច្នេះគ្រូគួរសាកសួរពីវិធីធ្វើសមាធិ សម្រាប់ជីវិតប្រចាំថ្ងៃ ពីសំណាក់លោកអ្នកដែលចេះដឹង។

## ទឹកចិត្តគ្រូបង្រៀន

**១.មេត្តាចិត្ត** ៖ គុណធម៌គឺសេចក្តីស្រឡាញ់ ការរាប់អានដ៏លើសលប់ ស្មោះស្មើចំពោះសិស្ស គឺរាប់អាន ដោយមិនរើសអើង មិនប្រកាន់ ទោះកូនអ្នកមាន កូនអ្នកក្រ ខ្មៅ ស ល អាក្រក់ ជានា វិកលវិការ ក៏ដោយក៏គ្រូនូវតែស្និទ្ធស្នាលដោយមេត្តាចិត្តនឹងសិស្សគ្រប់រូបដូចៗគ្នា។

**២.ករុណាចិត្ត** ៖ ទំហំចិត្តអាណិត ទឹកចិត្តអាសូរសិស្សានុសិស្ស ខណៈសិស្សរៀនមិនចេះ រៀនមិនចាំ ស្តាប់មិនយល់ ចាប់មិនបាន ឬពេលសិស្សជួបការខ្វះខាត គ្រោះថ្នាក់ ឧបសគ្គ ភយន្តរាយផ្សេងៗ។ ពេលសិស្សជួបឧបសគ្គ ទាំងការសិក្សា ទាំងជីវភាព គួរជួយផ្តល់ប្រឹក្សា រកគន្លឹះដោះស្រាយបញ្ហាដោយសន្តិវិធីមាន ឬជួយផ្តល់កម្លាំងចិត្ត និងផ្តល់សម្ភារៈខ្លះៗតាមដែលអាចធ្វើទៅបាន។

**៣.មុទិតាចិត្ត** ៖ ទំនោអារម្មណ៍ប្រកបដោយសាទរភាព គឺត្រេកអររីករាយតាមដែលសិស្សបានសុខបានសប្បាយ ក្នុងការសិក្សា។ រីករាយនឹងសិស្សដែល បានចេះ បានដឹង មានការងារធ្វើ មានកិត្តិយសខ្ពង់ខ្ពស់ធំមុខធំមាត់ក្នុងសង្គម។ គ្រូមិនគួសើចចំអក ឬបញ្ចើចបញ្ចើសិស្ស ខណៈសិស្សបានចម្រើនបានរុងរឿង បើទុកជាសិស្សមិនដឹងគុណក៏ដោយ ព្រោះថា បើសិស្សយើងអាចជួយខ្លួនឯងបាន នោះនឹងអាចជួយគ្រួសារគេ និងសង្គមជាតិទាំងមូលឲ្យបានរុងរឿងជាមិនខាន។

**៤.ឧបេក្ខាចិត្ត** ៖ ជាអព្យាកតចិត្ត មជ្ឈិមចិត្ត ចិត្តជាកណ្តាល ចិត្តល្មមៗ គឺរំពៃឃ្លាំមើលដំណើរការសិក្សា វាយតម្លៃការសិក្សាជាប្រចាំដោយចិត្តជាអជ្ឈាកណ្តាលមិនលំអៀង។ ទោះបីជាសិស្សអាចដោះស្រាយលំហាត់ ឬអនុវត្តមេរៀនបានយ៉ាងណា ក៏គ្រូមិនគួរបណ្តែតបណ្តោយឡើយ ចាំមើលជានិច្ច តាមដានជានិច្ច ក្រែងសិស្សមានចម្ងល់ក្នុងចំណុចណាមួយមិនច្បាស់លាស់ ។ ម្យ៉ាងទៀត គ្រូតែងតែរំពៃ ខ្លាចសិស្សធ្លោយខ្លួនទៅជាជនអន្ធពាល ធ្វើអំពើខុសឆ្គង គឺគ្រូតែងតែប្រដៅថាផ្តែផ្តាំរហូត ទោះជាសិស្សបែកឆ្ងាយពីគ្រូក៏ដោយ។

## ចំណុចដែលគ្រូត្រូវលះបង់

គ្រូជាមនុស្សស្មោះត្រង់ ជាតុលាការឯករាជ្យមួយ ដែលប្រកបទៅដោយសុក្រឹតភាព និងយុត្តិធម៌ក្នុងថ្នាក់រៀន មិនលម្អៀង មិនទទួលសំណូកពីសិស្សទេ។ ដូច្នេះ គ្រូត្រូវលះបង់ចោល នូវអគតិ៤ គឺ ៖

**១.ឆន្ទាគតិ** ៖លម្អៀងព្រោះស្រឡាញ់ ស្រឡាញ់សិស្សជ្រុល ពន្យល់តែម្នាក់ ប្រកាន់ពួកក្រុម និងលួចដាក់ពិន្ទុឲ្យច្រើនៗ តែសិស្សដែលខ្លួនពេញចិត្ត។

**២.ទោសាគតិ** ៖ លម្អៀងព្រោះខឹង ព្រោះស្អប់ ស្អប់សិស្សមួយណាខ្លាំង មិនយកចិត្តទុកដាក់ សោះអង្គើយ ព្រងើយកន្តើយ លួចកេងបន្ថយពិន្ទុ។

**៣.មោហាគតិ** ៖លម្អៀងព្រោះវង្វេងភាន់ច្រឡំ សំដៅលើគ្រូដែលមិនសូវ ឈ្លៀសប្រតិពល ក្នុងការបង្ហាត់ក្នុងការអប់រំ ខំប្រឹងទាំងងងឹតងងុល អាចលម្អៀងដោយការដាក់ពិន្ទុច្រឡំ ដាក់ពិន្ទុឲ្យអ្នកខុសបានច្រើន ឯអ្នកត្រូវបានតិច ។ ម្យ៉ាងទៀតក្នុងថ្នាក់រៀនសិស្សខ្លះខិលខូចបែររួចខ្លួន ឯសិស្សខ្លះធ្វើត្រឹមត្រូវ បែរជាត្រូវទទួលពិន័យ។ ចំណុចនេះ តម្រូវឲ្យគ្រូមានការពិនិត្យ និងវាយតម្លៃឲ្យបានច្បាស់លាស់។

**៤.ភយាគតិ** ៖ លម្អៀងព្រោះភ័យ ព្រោះខ្លាច ។ ដោយសារ សព្វថ្ងៃសិស្សទំនើង ពាលាអាវ៉ាសែកាចសាហាវមានចំនួន ហ៊ានសម្លុតគម្រាមគ្រូ ឬមាតាបិតាសិស្សជាអ្នកខ្ពង់ខ្ពស់ ខ្លាចគេរករឿង ក៏ដាក់ពិន្ទុឲ្យជាប់លេខ ១ ជាដើម។

ឲឲឲ❋ឱឱឱ

## ឯកសារពិគ្រោះ


| | | | |
|---|---|---|---|
| -សុត្តបិដក លេខ១៩ | ពុទ្ធសាសនបណ្ឌិត | -វចនានុក្រមខ្មែរ | សម្តេចសង្ឃ ជួន ណាត |
| -មង្គលត្ថទីបនី ភាគ៣ | ពុទ្ធសាសនបណ្ឌិត | -សិក្ខាបទមនុស្សល្អ | អគ្គបណ្ឌិត ប៊ុត សាវង្ស |
| -មង្គលត្ថទីបនីប្រែ ៣ | ព្រះមហាឃិន នឿន | -ព្រះបាទធម្មិក | ធម្មបណ្ឌិត ហេង មណីចិន្តា |
| -ឧបករណ៍ធម្មវិភាគ | ពុទ្ធសាសនបណ្ឌិត | -ជីវិតអាពាហ៍ពិពាហ៍ | ធម្មបណ្ឌិត ហេង មណីចិន្តា |
| -សិង្គាលសូត្រ | បណ្ឌិត ស្រី ធម្មានន្ទ | -មង្គលសូត្រ | ឃិន វន |

# ព្រះគុណគ្រូ

ម្លប់គ្រូអាចារ្យ គរុធាយា សិស្សាចងចាំ
ម្លប់សែនត្រជាក់ ត្រជុំប្រចាំ ត្រឈៃរាល់ឆ្នាំ
ដឹកនាំសិក្សា ។

គ្រូប្រឹងប្រដៅ សិស្សឆោតល្ងង់ខ្លៅ ឲ្យមានប្រាជ្ញា
ស្គាល់ជាតិស្គាល់សាសន៍ ច្បាស់ទាំងចរិយា សីលធម៌ល្អថ្លា
ខេមរាធ្លាប់មាន ។

ទោះគ្រូក្រកី លំបាកម្តេចក្តី ស៊ូស្តីទូន្មាន
ប្រិតប្រៀនឲ្យចេះ ចំណេះជាស្ពាន ជំនាញជាយាន
ឈានសាងសង្គម ។

គ្រូជួយកូនខ្មែរ ទាំងចម្ការស្រែ ជួនថៃអបរំ
ឲ្យចេះឱនអង្គ ព្រះសង្ឃចាស់ទុំ សីលធម៌មនោរម្យ
និងប្រពៃណី ។

គ្រូព្យាបាលរោគ ល្វឹតល្ងង់លើលោក មកជាមុនី
អ្នកប្រាជ្ញកវី ល្បីសព្វទិសទី តម្កើងធានី
ដែនដីកម្ពុជា ។

ក្រុមវិស្វករ ច្នៃព្រលឹងល្អ ពេញដោយវិជ្ជា
ចំណេះកបកើន ក្រើនសិស្សគ្រប់គ្នា គោរពវន្ទា
គុណគ្រូឧត្តម ។